ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ:១៤០០ ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញា រដ្ឋបាលស្រុកកំពង់ត្រាច ខេត្តកំពត

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តកំពត

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតនិមិត្តសញ្ញារដ្ឋបាលស្រុកកំពង់ត្រាច ខេត្តកំពត មានរូបរាង រូបភាព និងលក្ខណៈសម្គាល់ដូចខាងក្រោម៖ ក.ខ

- និមិត្តសញ្ញាមានរាងមូលព័ទ្ធដោយខ្សែវណ្ឌពណ៌មាស និងព័ទ្ធដោយកម្រងផ្លែម្រេចពណ៌បៃតង បង្ហាញអំពីការគ្រប់គ្រងដែនដីរបស់រដ្ឋបាលស្រុក
- ភ្នំកំពង់ត្រាចគ្របដណ្ដប់ដោយរុក្ខជាតិមានពណ៌បៃតង ជាតំណាងនៃភ្នំធម្មជាតិតាំងពីបុរាណកាលរហូតដល់បច្ចុប្បន្ន។ ភ្នំកំពង់ត្រាចមានរូង និងល្អាងទឹកពីធម្មជាតិ ហើយជាទីកន្លែងជម្រកសត្វព្រៃនិងបក្សាបក្សី ហើយក៏ជាទីកន្លែងគោរពបូជា បន់ស្រន់ និងជារមណីយដ្ឋានវប្បធម៌និងប្រវត្តិសាស្ត្រសម្រាប់អ្នកទេសចរទាំងជាតិនិងអន្តរជាតិ
- ផ្ទៃទឹកពណ៌ខៀវខ្ចី បង្ហាញអំពីប្រភពទឹកមិនចេះរីងស្ងួតទាំងរដូវប្រាំងនិងរដូវវស្សា ដែលមានប្រព័ន្ធធារាសាស្ត្រសម្រាប់ស្រោចស្រពដំណាំស្រូវ ដំណាំហូបផ្លែ និងបន្លែបង្ការ ព្រមទាំងជាជម្រកមច្ឆជាតិ
- កម្រងផ្លែម្រេចពណ៌បៃតង បង្ហាញអំពីភាពលូតលាស់ដំណាំម្រេច ដែលដាំដុះតាំងពីសម័យដើមរហូតដល់សព្វថ្ងៃនេះ ហើយក៏ជាម្រេចដែលមានគុណភាពខ្ពស់ សម្រាប់បម្រើទីផ្សារក្នុងស្រុកនិងក្រៅស្រុក
- អក្សរឈ្មោះ«**រដ្ឋបាលស្រុកកំពង់ត្រាច**»មានពណ៌ស រំលេចក្នុងខ្សែបូពណ៌ក្រហមអមដោយខ្សែបូពណ៌ខៀវនិងពណ៌លឿង ទ្រដោយក្បាច់ផ្កាភ្ញីទេសពណ៌មាសរចនាតាមបែបសិល្បៈ និងវប្បធម៌ខ្មែរ
- ផ្ទៃពណ៌ស បង្ហាញអំពីភាពជឿជាក់ ភាពស្មោះត្រង់ និងភាពត្រជាក់ត្រជុំ។

**ប្រការ២ ._**

ត្រូវបានដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកកំពង់ត្រាច ខេត្តកំពត ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

និមិត្តសញ្ញារដ្ឋបាលស្រុកកំពង់ត្រាច ខេត្តកំពត ត្រូវប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារនៅរដ្ឋបាលស្រុកកំពង់ត្រាច
- ប្រើប្រាស់នៅលើលិខិត ស្រោមសំបុត្រ និងឯកសារផ្លូវការពាក់ព័ន្ធរបស់រដ្ឋបាលស្រុកកំពង់ត្រាច
- ប្រើប្រាស់ក្នុងពិធីនានា និងប្រើប្រាស់ក្នុងកិច្ចការជាផ្លូវការផ្សេងៗតាមការចាំបាច់។

**ប្រការ៣ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ ._**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស ប្រធានអង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សាខេត្តកំពត អភិបាលនៃគណៈអភិបាលខេត្តកំពត ប្រធានក្រុមប្រឹក្សាស្រុកកំពង់ត្រាច និងអភិបាលនៃគណៈអភិបាលស្រុកកំពង់ត្រាច ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧ កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលខេត្តកំពត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ...១៤០០...ប្រក ចុះថ្ងៃ...សុក្រ...៣...កើត...ខែ...មាឃ.... ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៨...ខែ...កុម្ភៈ...ឆ្នាំ២០២៥ ស្តីពីការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកកំពង់ត្រាច ខេត្តកំពត។

**និមិត្តសញ្ញារដ្ឋបាលស្រុកកំពង់ត្រាច**